**របាយការណ៍បូកសរុប**

**លទ្ធផលសន្និសីទអន្តរជាតិ លើកទី២**

**ស្តីពី "កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ក្រោមប្រធានបទ ៖ អភិវឌ្ឍធនធានមនុស្ស ដើម្បីការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាព"**

**ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ នៅសណ្ឋាគារសុខាភ្នំពេញ (ស៊ីជង់) រាជធានីភ្នំពេញ**

**ដោយ**

**ឯកឧត្តម ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍**

*សូមគោរព៖*

- ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***
- ***ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី***
- ***ឯកឧត្តម លោកជំទាវ អគ្គរាជទូត អគ្គរដ្ឋទូត នៃប្រទេសជាសមាជិកអាស៊ាន***
- *ឯកឧត្តម Tran Dong Phuong អគ្គនាយកអភិវឌ្ឍ និងជាតំណាងអគ្គលេខាធិការអាស៊ាន*
- ***ឯកឧត្តម លោកជំទាវ តំណាងស្ថាប័នទេសចរណ៍អាស៊ាន***
- ***ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ** និងអង្គសន្និសីទ ទាំងមូលជាទីមេត្រី!*

ថ្ងៃនេះ ជាទិវាប្រកបដោយនក្ខត្តឫក្សដ៏ឧត្តុងឧត្តម ដែលយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំនៃក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ តំណាងលេខាធិការដ្ឋានអាស៊ាន ថ្នាក់ដឹកនាំស្ថាប័នទេសចរណ៍នៃប្រទេសជាសមាជិកអាស៊ាន និងអង្គសន្និសីទទាំងមូលនៅទីនេះ មានកិត្តិយស និងមោទនភាពបំផុត ដែលបានទទួលស្វាគមន៍ដោយក្តីរំភើបរីករាយក្រៃលែង ចំពោះវត្តមានដ៏ឧត្តុងឧត្តមបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹក អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទ**សន្និសីទអន្តរជាតិលើកទី ២ ស្តីពី "កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ក្រោមប្រធានបទ ៖ អភិវឌ្ឍធនធានមនុស្ស ដើម្បីការអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព"** នាពេលនេះ។

តាងនាមឲ្យអង្គសន្និសីទទាំងមូល និងក្នុងនាមខ្ញុំបាទផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ចស្វាគមន៍ប្រកបដោយកត្តញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកអញ្ជើញមកលើកទឹកចិត្តដល់សន្និសីទអន្តរជាតិទាំងមូលនាពេលនេះ ធ្វើឲ្យយើងខ្ញុំមានមោទនភាពក្រៃលែង និងត្រៀមទទួលការណែនាំ ព្រមទាំងអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់យកទៅអនុវត្ត ដើម្បីឲ្យវិស័យទេសចរណ៍កម្ពុជា និងអាស៊ានកាន់តែរីកចម្រើនថែមទៀត។

- ***សម្តេចអគ្គមហាសេនាបតី*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*
- *អង្គសន្និសីទទាំងមូលជាទីមេត្រី!*

ក្នុងឱកាសដ៏មហាប្រសើរនេះ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** អំពីដំណើរការ និងលទ្ធផលនៃអង្គសន្និសីទដូចតទៅ៖

អង្គសន្និសីទអន្តរជាតិ លើកទី២ នេះ បានដំណើរការចាប់ពី**ថ្ងៃទី២០ ដល់ ២១ ខែមិថុនា ឆ្នាំ២០១៨** ដោយមានការចូលរួមពី អគ្គនាយកអភិវឌ្ឍន៍ និងជាតំណាងអគ្គលេខាធិការអាស៊ាន ថ្នាក់ដឹកនាំស្ថាប័នទេសចរណ៍មកពីប្រទេសសមាជិកអាស៊ាន មជ្ឈមណ្ឌលអាស៊ាន-ចិន មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន សាកលវិទ្យាល័យ និងសាលាបណ្តុះបណ្តាលនៃប្រទេសអាស៊ាន សមាគមទេសចរណ៍អាស៊ាននានា អង្គការជាតិ-អន្តរជាតិ ដៃគូអភិវឌ្ឍន៍ វាគ្មិនជាតិ-អន្តរជាតិ ក្រសួង-ស្ថាប័នជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សមត្ថកិច្ចពាក់ព័ន្ធ សាកលវិទ្យាល័យ និង សាលាបណ្តុះបណ្តាលវិជ្ជាជីវៈជាតិ ផ្នែកឯកជន យុវជន សិស្ស-និស្សិត សរុបប្រមាណជាង **១០០០នាក់** ហើយរូបខ្ញុំបាទផ្ទាល់ បានធ្វើជាអធិបតីក្នុងពិធីបើកសន្និសីទអន្តរជាតិនេះ កាលពីព្រឹកថ្ងៃ**ទី២០ ខែមិថុនា ឆ្នាំ២០១៨** ម្សិលមិញនេះ។

អង្គសន្និសីទបានវាយតម្លៃខ្ពស់ចំពោះវាគ្មិនជាតិ និងអន្តរជាតិ ដែលបានពិភាក្សាយ៉ាងផុលផុស និងចែករំលែកចំណេះដឹង បទពិសោធន៍ល្អៗ និងទស្សនទានថ្មីៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យទេសចរណ៍ សំដៅជំរុញការអភិវឌ្ឍវិស័យទេសចរណ៍អាស៊ាន ប្រកបដោយនិរន្តរភាព និងក្លាយជាគោលដៅទេសចរណ៍តែមួយ ប្រកបដោយភាពទាក់ទាញ និងគុណភាពខ្ពស់។ កិច្ចពិភាក្សាបានផ្តោតសំខាន់លើប្រធានបទ**ចំនួន ៥** រួមមាន៖

**ប្រធានបទទី១៖ បញ្ហាប្រឈមក្នុងការផ្តល់សេវាកម្មទេសចរណ៍ប្រកបដោយគុណភាព នៅក្នុងបរិបទ នៃការប្រកួតប្រជែងពិភពលោក** សម្របសម្រួលដោយ **លោក Paul Pruangkarn** នាយកគ្រប់គ្រងផ្នែកទំនាក់ទំនង និងទីផ្សារនៃសមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិក (PATA)។

**ប្រធានបទទី២៖ ការងារ និងកំណើនសេដ្ឋកិច្ច៖ តើវិស័យទេសចរណ៍ដើរតួនាទីយ៉ាងដូចម្តេចក្នុងការបង្កើតឱកាសការងារ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកប្រកបដោយនិរន្តរភាព ?** សម្របសម្រួលដោយ **លោក** Jan Hansen សេដ្ឋវិទូជាន់ខ្ពស់ នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំកម្ពុជា។

**ប្រធានបទទី៣៖ កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន (MRA-TP) និងក្របខ័ណ្ឌគតិយុត្ត** សម្របសម្រួល **ដោយលោក** I Gusti Putu laksaguna ប្រធានក្រុមប្រឹក្សាភិបាលអ្នកជំនាញទេសចរណ៍ជាតិ នៃប្រទេសឥណ្ឌូណេស៊ី (NTPB)។

ប្រធានបទទី៤៖ **ការទទួលស្គាល់គុណវុឌ្ឍិអាស៊ានជា "គោលដៅអនាគតនៃការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍"** សម្របសម្រួលដោយ **លោក Eddy Krismeidi** Soemawilaga ប្រធានទំនាក់ទំនងរដ្ឋាភិបាលនៃក្រុមហ៊ុនអាកាសចរ Air Asia និងជាអតីតមន្ត្រីជាន់ខ្ពស់លេខាធិការដ្ឋានអាស៊ាន ទទួលបន្ទុកសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀង MRA-TP។

ប្រធានបទទី៥៖ **កិច្ចពិភាក្សាអំពី** ASEAN MRA-TP - **ស្ដីពីវិថីឆ្ពោះទៅកាន់កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន** សម្របសម្រួលដោយ **លោក Wayne Crosbie** នាយកផ្នែកអភិវឌ្ឍធុរៈកិច្ច និងសហប្រតិបត្តិការអន្តរជាតិ នៃវិទ្យាស្ថាន William Angliss ប្រទេសអូស្ត្រាលី។

- ***សម្តេចអគ្គមហាសេនាបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***
- *អង្គសន្និសីទទាំងមូលជាទីមេត្រី!*

ឆ្លងតាមរយៈកិច្ចពិភាក្សាពីសំណាក់វាគ្មិនជាតិ-អន្តរជាតិ និងកិច្ចពិភាក្សាយ៉ាងផុលផុស អង្គសន្និសីទទទួលបានលទ្ធផលដូចខាងក្រោម៖

**ទី១៖** អង្គសន្និសីទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់**ថ្នាក់ដឹកនាំកំពូលនៃប្រទេស CLMV** ដែលបានគាំទ្រកម្ពុជា ក្នុងការរៀបចំ**សន្និសីទអន្តរជាតិលើកទី ២ ស្តីពី "កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន"** ដូចដែលមានបញ្ជាក់នៅក្នុងសេចក្តីប្រកាសព័ត៌មានរួម នៃកិច្ចប្រជុំកំពូល**លើកទី ៩** នៃកិច្ចសហប្រតិបត្តិការ **កម្ពុជា ឡាវ ភូមា និងវៀតណាម** (CLMV) កាលពីថ្ងៃទី **១៦ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ** កន្លងមកនេះ។ អង្គសន្និសីទសូមថ្លែងអំណរគុណដល់កម្ពុជា ដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទនេះឡើង ជាពិសេសសូមគោរពថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹកអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និសីទអន្តរជាតិនេះ ដែលនេះជាការផ្តល់កិត្តិយសដ៏ឧត្តុងឧត្តម និងលើកទឹកចិត្តដល់ការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន។

**ទី២៖** អង្គសន្និសីទបានកត់សម្គាល់ពីភាពរីកចម្រើននៃបច្ចេកវិទ្យាពិភពលោក ដែលមានឥទ្ធិពលលើប្រព័ន្ធ និងសមាសធាតុនៃអភិក្រមការអប់រំបណ្តុះបណ្តាល ក្នុងនោះប្រទេសជាសមាជិកអាស៊ានត្រូវគិតគូរអំពីការរៀបចំគំរូ នៃការបណ្តុះបណ្តាលស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ក្នុង**យុគ្គសម័យបដិវត្តឧស្សាហកម្ម ៤.០** ខណៈបច្ចេកវិទ្យានឹងចូលរួមបង្កើតការងារថ្មីៗបន្ថែមទៀត ដូច្នេះការបណ្តុះបណ្តាលត្រូវតម្រង់ទិសយុវជនឲ្យមានលទ្ធភាពត្រៀមទទួលយកជំនាញថ្មីៗបន្ថែមទៀតនាពេលបច្ចុប្បន្ន និងអនាគត។ អង្គសន្និសីទ ក៏បាន

មើលឃើញពីសារៈសំខាន់នៃការសំយោគបញ្ចូលគ្នា ដោយត្រូវរៀបចំកម្មវិធី និងប្រព័ន្ធបណ្តុះបណ្តាលក្នុងតំបន់អាស៊ាន ដែលជាមូលដ្ឋានរួមប្រកបដោយភាពបត់បែនស្របតាមស្ថានភាពជាក់ស្តែងនៃប្រទេសជាសមាជិកនីមួយៗ។

**ទី៣៖** អង្គសន្និសីទយល់ឃើញពីភាពចាំបាច់នៃតួនាទីរបស់ភាគីឯកជន ក្នុងការចូលរួមបណ្តុះបណ្តាលដោយផ្ទាល់នៅទីតាំងអាជីវកម្ម ដើម្បីរក្សាមូលធនមនុស្សក្នុងក្រុមហ៊ុនអាជីវកម្មរបស់ខ្លួនផង ក៏ដូចជាផ្សារភ្ជាប់ការសិក្សាក្នុងថ្នាក់ទៅនឹងការអនុវត្តជាក់ស្តែងផង។

**ទី៤៖** អង្គសន្និសីទបានកត់សម្គាល់ពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នរដ្ឋ និងឯកជន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ ក្នុងការជំរុញការវាយតម្លៃ និងបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍ប្រកបដោយគុណភាព និងផលិតភាពការងារខ្ពស់ ជាពិសេសក្នុងស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក លើអ្នកជំនាញទេសចរណ៍អាស៊ាន (ASEAN MRA-TP)។

**ទី៥៖** អង្គសន្និសីទបានគូសបញ្ជាក់ពី**ភាពចាំបាច់** ក្នុងការ**ជំរុញការសិក្សាពេញមួយជីវិត (Lifelong Learning)** តាមរយៈការដាក់ចុះនូវវិថីអភិវឌ្ឍជំនាញ (Career Pathway) ដែលក្នុងនោះត្រូវគិតគូរដល់ការបណ្តុះបណ្តាលអ្នកជំនាញថ្មី និងអ្នកជំនាញកំពុងបម្រើការងារបច្ចុប្បន្ន តាមរយៈ**ការវាយតម្លៃការសិក្សាពីមុន** (Recognition of Prior Learning) និងការពង្រឹងសមត្ថភាពបន្ថែម។

**ទី៦៖** អង្គសន្និសីទបានកត់សម្គាល់ពី**ភាពចាំបាច់**របស់វិស័យទេសចរណ៍ ក្នុងការចូលរួមសម្រេចគោលដៅប្រកបដោយនិរន្តរភាព (SDGs) របស់អង្គសហប្រជាជាតិ ជាពិសេសតាមរយៈការអប់រំបណ្តុះបណ្តាលអ្នកជំនាញទេសចរណ៍។

**ទី៧៖** អង្គសន្និសីទបានកោតសរសើរ និងអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ ឆ្លើយតបទៅនឹងកិច្ចព្រមព្រៀង MRA-TP និងដែលបានជំរុញការបង្កើតសាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ និងវិទ្យាស្ថានជាតិទេសចរណ៍ ព្រមទាំងបង្កើតឲ្យមានគោលនយោបាយក្នុងការទទួលស្គាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ឯកជនជាដៃគូ ក្នុងការអនុវត្តកម្មវិធីសិក្សាអាស៊ាន (ASEAN MRA-TP)។ អង្គសន្និសីទបានអបអរសាទរ និងថ្លែងអំណរគុណដល់ដៃគូរអភិវឌ្ឍន៍ដូចជា ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ដែលបានជួយបង្កើតសាលាជាតិបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ ទីភ្នាក់ងារអន្តរជាតិអភិវឌ្ឍន៍ និងសហប្រតិបត្តិការស៊ុយអែត (SIDA) និងមូលនិធិ Shift 360 ដែលបានជួយបង្កើតសាលាម្ហូបអាហារកម្ពុជា (ACAC) និងវិទ្យាស្ថានជាតិទេសចរណ៍ និងបដិសណ្ឋារកិច្ច ខេត្តយូណាន ដែលជួយបង្កើតវិទ្យាស្ថានជាតិទេសចរណ៍នៅកម្ពុជា។

**ទី៨៖** អង្គសន្និសីទបានអបអរសាទរចំពោះធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយចំនួននៅកម្ពុជាក្រោមការគាំទ្ររបស់រាជរដ្ឋាភិបាល ដែលបានដាក់ចេញអនុវត្តនូវកម្មវិធីឥណទានកម្ចីដល់សិស្ស សម្រាប់ជំនាញទេសចរណ៍ (Study Loans for Tourism Skills)។

**ទី៩៖** អង្គសន្និសីទបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលរបស់កម្ពុជា ក្នុងការបង្កើតឲ្យមានកម្មវិធីបណ្តុះបណ្តាលជំនាញទេសចរណ៍តាមស្តង់ដាអាស៊ាន នៅតាម**វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស** ដោយសហការជាមួយ**ក្រសួងអប់រំ យុវជន និងកីឡា** ក៏ដូចជា**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**ផងដែរ។ កម្មវិធីបណ្តុះបណ្តាលនេះនឹងចូលរួមផ្តល់ជំនាញទេសចរណ៍ដល់យុវជនកម្ពុជា តាំងពីការសិក្សានៅកម្រិតវិទ្យាល័យ ហើយជាមូលដ្ឋានក្នុងការអភិវឌ្ឍអាជីពក្នុងវិស័យទេសចរណ៍ពេញមួយជីវិត។

**ទី១០៖** អង្គសន្និសីទបានអបអរសារទរដល់សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ **ចំនួន៩** ក្នុងបណ្តាប្រទេសអាស៊ានចំពោះកិច្ចខិតខំប្រឹងប្រែង និងការចូលរួមបណ្តុះបណ្តាលសិស្សនិស្សិតតាមយន្តការអាស៊ាន ហើយដែលលេខាធិការដ្ឋានអាស៊ាន បានសម្រេចប្រគល់បណ្ណសរសើរ ព្រឹកមិញនេះ រួមមាន៖

- **កម្ពុជា** មានចំនួន **២** គឺ៖
  - **សាលាសណ្ឋាគារ និងទេសចរណ៍ ប៉ូល ឌុយ ប្រ៊ូល** នៅខេត្តសៀមរាប និង
  - **សាលាបដិសណ្ឋារកិច្ច និងទេសចរណ៍ ប៉េ អេស អឺ** នៅរាជធានីភ្នំពេញ
- **ឥណ្ឌូនេស៊ី** មានចំនួន **២គឺ៖**
  - **សាលាទេសចរណ៍ Tinggi Bandung**
  - **សាលាប៉ូលីទិកនិច និងទេសចរណ៍ Negeri Makassar**
- **ឡាវ** មានចំនួន **១គឺ៖ វិទ្យាស្ថាន Mass Media, Culture, and Tourism**
- **ភូមា** មានចំនួន **២គឺ៖**
  - **វិទ្យាស្ថាន TRC Hotel and Vocational Training**
  - **វិទ្យាស្ថាន Star Resources Academy**
- **វៀតណាម** មានចំនួន **២គឺ៖**
  - **មហាវិទ្យាល័យ Hue Tourism College**
  - **មហាវិទ្យាល័យ Pegasus International College**

**ទី១១៖** អង្គសន្និសីទបានដាក់ចេញនូវសេចក្តីប្រកាសព័ត៌មានរួម (Joint Media Statement) ស្តីពី "**កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍អាស៊ាន ក្រោមប្រធានបទ ៖ អភិវឌ្ឍធនធានមនុស្ស ដើម្បីការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាព**" ដោយប្រមូលផ្តុំសំខាន់ទៅលើ៖

១. លើកទឹកចិត្តឲ្យមានការអនុវត្ត**ស្តង់ដាសមត្ថភាពរួម**អ្នកជំនាញទេសចរណ៍អាស៊ាន (ACCSTP) **ស្តង់ដាបណ្តុះបណ្តាលរួម**អាស៊ាន (CATC) និងឧបករណ៍ចាំបាច់មួយចំនួនទៀត នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលបដិសណ្ឋារកិច្ច និងទេសចរណ៍ ដើម្បីលើកកម្ពស់ ស្តង់ដាគុណភាពការបណ្តុះបណ្តាល។

២. សម្រួលការបម្លាស់ទីអ្នកជំនាញទេសចរណ៍ ដែលមានការទទួលស្គាល់នៅក្នុងតំបន់ ស្រប តាមវិធាននានានៃក្របខ័ណ្ឌគតិយុត្ត គោលនយោបាយ និងគោលការណ៍ច្បាប់នៃ ប្រទេសសមាជិកនីមួយៗ។

- ***សម្តេចអគ្គមហាសេនាបតីតេជោ*** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*
- *អង្គសន្និសីទទាំងមូលជាទីមេត្រី!*

តាមរយៈកិច្ចពិភាក្សា និងស្មារតីអង្គសន្និសីទខាងលើ លេខាធិការដ្ឋានអាស៊ាន ក្រសួងទេសចរណ៍ និងគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានធាតុចូលថ្មីៗ បន្ថែមទៀតក្នុងការដឹកនាំ និងអភិវឌ្ឍធនធានមនុស្ស ដើម្បីសហការអភិវឌ្ឍន៍វិស័យទេសចរណ៍ ប្រកបដោយនិរន្តរភាព។

ជាថ្មីម្តងទៀត តាងនាមឲ្យអង្គសន្និសីទទាំងមូល ខ្ញុំបាទសូមសម្តែងនូវការថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅបំផុតចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ និងមមាញឹក អញ្ជើញជាធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និសីទអន្តរជាតិ**លើកទី ២** នេះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរមហាប្រសើរ និងបួងសួងដល់ទេវតារក្សាព្រះរាជាណាចក្រ កម្ពុជា សូមជួយបីបាច់ថែរក្សា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងក្រុមគ្រួសារ សូមទទួលបាននូវសុខភាពបរិបូរណ៍ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីបន្តដឹកនាំនាវាកម្ពុជាក្នុងសុខសន្តិភាព ស្ថេរភាព និងភាពសម្បូរ រុងរឿងនៃមាតុភូមិកម្ពុជា។

ដើម្បីទទួលបានអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ដល់អង្គសន្និសីទទាំងមូល ខ្ញុំបាទសូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មាន ប្រសាសន៍សំណេះសំណាល និងថ្លែងសន្ទរកថាបិទអង្គសន្និសីទ។

***សូមគោរពអញ្ជើញ!***